# ទម្រង់បែបបទចាត់តាំងភ្នាក់ងារជាជំនួយការដល់អ្នកបោះឆ្នោត

សម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពជាប់ខ្លួនដែលត្រូវការជំនួយក្នុងការទៅទទួលយក ឬផ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ត្រឡប់មកវិញ

Pennsylvania Department of State

## តើទម្រង់បែបបទនេះសម្រាប់អ្វីដែរ?

ប្រើទម្រង់បែបបទនេះដើម្បីជ្រើសរើសនរណាម្នាក់សម្រាប់ជួយអ្នក បោះឆ្នោតតាមប្រៃសណីយ៍។
មនុស្សដែលអ្នកជ្រើសរើសគឺជាភ្នាក់ងារដែលអ្នកបានចាត់តាំង។ ភ្នាក់ងារដែលអ្នកបានចាត់តាំងអាចៈ

- ទៅទទួល និងប្រគល់ពាក្យសុំ សន្លឹកឆ្នោតបោះតាមប្រៃសណីយ៍ ឬសន្លឹកឆ្នោតអវត្តមាន របស់អ្នក។
- ទៅទទួល និងប្រគល់សន្លឹកឆ្នោតបោះតាមប្រៃសណីយ៍ ឬសន្លឹកឆ្នោតអវត្តមានរបស់អ្នកមកវិញ។
- ផ្តល់ជំនួយផ្សេងទៀតដែលអ្នកត្រូវការក្នុងការបោះឆ្នោត។

## តើអ្នកណាខ្លះអាចប្រើទម្រង់បែបបទនេះ?

អ្នកអាចប្រើទម្រង់បែបបទនេះ ប្រសិនបើអ្នកមានពិការភាពជាប់ ខ្លួន ហើយត្រូវការជំនួយក្នុងការមកទទួល ឬការប្រគល់សន្លឹកឆ្នោតរបស់អ្នក ឬឯកសារបោះឆ្នោតផ្សេងទៀតត្រឡប់មកវិញ។

## តើខ្ញុំប្រើទម្រង់បែបបទនេះដោយរបៀបណាដែរ?

1. បំពេញព័ត៌មានត្រង់ផ្នែកពាក់កណ្តាលខាងលើនៃទម្រង់បែបបទនេះ។
2. ឱ្យភ្នាក់ងារដែលអ្នកបានចាត់តាំងបំពេញព័ត៌មានពាក់កណ្តាលខាងក្រោមនៃបែបបទនេះ។
3. ប្រការដែលល្អ សូមអ្នកថតចម្លងទម្រង់បែបបទដែលបានបំពេញព័ត៌មានរួចរាល់ ដើម្បីរក្សាទុក (រូបថតតាមទូរស័ព្ទ ក៏អាចប្រើបានដែរ)។ រក្សាសំណៅថតចម្លងទុក ហើយផ្តល់ទម្រង់បែបបទដើមទៅភ្នាក់ងារដែលអ្នកបានចាត់តាំង។
4. ភ្នាក់ងារដែលអ្នកបានចាត់តាំងត្រូវតែមានទម្រង់បែបបទដែលបានបំពេញព័ត៌មានត្រឹមត្រូវជាប់ខ្លួន នៅពេលគាត់ទៅយក ឬប្រគល់សន្លឹកឆ្នោតរបស់អ្នក ឬឯកសារបោះឆ្នោតផ្សេងទៀតត្រឡប់មកវិញ។

នៅពេលបោះឆ្នោត
សូមកុំយកទម្រង់បែបបទនេះដាក់ក្នុងស្រោមសំបុត្រសម្ងាត់ពណ៌លឿងជាមួយសន្លឹកឆ្នោតដែលបានបំពេញ ហើយ។

## តើនរណាអាចជាភ្នាក់ងារដែលខ្ញុំចាត់តាំងបាន?

អ្នកអាចជ្រើសរើសនរណាម្នាក់ឱ្យធ្វើជាភ្នាក់ងារដែលអ្នកបានចាត់តាំង លើកលែងតែៈ

- និយោជករបស់អ្នក ឬភ្នាក់ងារ របស់និយោជកអ្នក។
- មន្ត្រី ឬ ភ្នាក់ងារសហជីពរបស់អ្នក។

*វាជារឿងមិនស្របច្បាប់ ដែលមាននរណាម្នាក់បំភិតបំភ័យ ឬបង្ខិតបង្ខំអ្នកក្នុងការអនុវត្តសិទ្ធិរបស់អ្នកក្នុងការបោះឆ្នោត។*

## តើខ្ញុំទទួលបានព័ត៌មានអំពីការបោះឆ្នោតតាមប្រៃសណីយ៍ដោយរបៀបណា?

សូមចូលទៅកាន់គេហទំព័រ vote.pa.gov/mailballot ឬទូរសព្ទទៅលេខ 1-877-868-3772 ឬគណៈកម្មការបោះឆ្នោតប្រចាំខោនធីរបស់អ្នក។

# ទម្រង់បែបបទចាត់តាំងភ្នាក់ងារជាជំនួយការដល់អ្នកបោះឆ្នោត

សម្រាប់អ្នកបោះឆ្នោតដែលមានពិការភាពជាប់ខ្លួនដែលត្រូវការជំនួយក្នុងការទៅទទួលយក ឬផ្ញើសន្លឹកឆ្នោត តាមប្រៃសណីយ៍ត្រឡប់មកវិញ

Pennsylvania
Department of State

## អ្នកបោះឆ្នោត សូមបំពេញផ្នែកនេះ

បញ្ចូលអាសយដ្ឋានដែលអ្នកបានចុះឈ្មោះបោះឆ្នោត។

អ្នកគួររក្សាច្បាប់ចម្លងនៃទម្រង់បែបបទនេះទុកមួយច្បាប់ (ថតរូប តាមទូរស័ព្ទក៏អាចប្រើបានដែរ)។

ផ្តល់ទម្រង់ដែលបានបំពេញព័ត៌មានរួចរាល់ទៅឱ្យភ្នាក់ងារដែលអ្នកបានចាត់តាំង។
សូមកុំដាក់ទម្រង់បែបបទនេះក្នុងស្រោមសំបុត្រសម្ងាត់ពណ៌លឿងជាមួយសន្លឹកឆ្នោតរបស់អ្នកដែលបានបំពេញហើយ។

នាមខ្លួន ______ ឈ្មោះកណ្តាល/ឈ្មោះដាក់អក្សរកាត់ ______

នាមត្រកូល ______ បច្ច័យ ______

អាសយដ្ឋាន ______

ទីក្រុង/ទីប្រជុំជន ______ រដ្ឋ ______ លេខកូដតំបន់ ______

ខោនធី ______

ឈ្មោះភ្នាក់ងារដែលអ្នកចាត់តាំង

ខ្ញុំបាទ/នាងខ្ញុំ មានពិការភាពជាប់ខ្លួន ហើយត្រូវការជំនួយក្នុងការបោះឆ្នោតតាមប្រៃសណីយ៍។ ខ្ញុំបាទ/នាងខ្ញុំ
អនុញ្ញាតឱ្យភ្នាក់ងារដែលបានចាត់តាំងរបស់ខ្ញុំទៅយក និងឬប្រគល់ឯកសារសន្លឹកឆ្នោតអវត្តមាន
ឬសន្លឹកឆ្នោតបោះតាមប្រៃសណីយ៍របស់ខ្ញុំបាទ/នាងខ្ញុំមកវិញ។
ខ្ញុំបាទ/នាងខ្ញុំយល់ថាការថ្លែងមិនពិតអាចរងការផ្តន្ទាទោសក្រោមច្បាប់ 18 Pa. C.S. § 4904។

ប្រសិនបើខ្ញុំបាទ/នាងខ្ញុំមិនអាចចុះហត្ថលេខាដោយគ្មានជំនួយដោយសារតែខ្ញុំបាទ/នាងខ្ញុំមានពិការភាពជាប់ខ្លួន
ខ្ញុំបានគូសសញ្ញាសម្គាល់របស់ខ្ញុំបាទ/នាងខ្ញុំ
ឬមាននរណាម្នាក់បានជួយខ្ញុំបាទ/នាងខ្ញុំគូសសញ្ញាសម្គាល់របស់ខ្ញុំបាទ/នាងខ្ញុំ។

**ហត្ថលេខារបស់អ្នកបោះឆ្នោត** ______

កាលបរិច្ឆេទថ្ងៃនេះ ______

## ភ្នាក់ងារដែលបានចាត់តាំង សូមបំពេញផ្នែកនេះ

បន្ទាប់ពីអ្នកបានបំពេញទម្រង់បែបបទនេះហើយ សូមថតចម្លងវាទុកសម្រាប់អ្នកបោះឆ្នោត (ថតរូប តាមទូរស័ព្ទក៏អាចប្រើបានដែរ)។

**អ្នកត្រូវយកទម្រង់បែបបទដែលបានបំពេញព័ត៌មានរួចរាល់មកមួយ អ្នកពេលទៅយក ឬប្រគល់សន្លឹកឆ្នោត ឬឯកសារបោះឆ្នោតផ្សេងទៀតមកវិញ។**

សូមកុំដាក់ទម្រង់បែបបទនេះក្នុងស្រោមសំបុត្រសម្ងាត់ពណ៌លឿងដែលមានសន្លឹកឆ្នោតដែលបានបំពេញហើយ។

នាមខ្លួន ______ ឈ្មោះកណ្តាល/ឈ្មោះដាក់អក្សរកាត់ ______

នាមត្រកូល ______ បច្ច័យ ______

អាសយដ្ឋាន ______

ទីក្រុង/ទីប្រជុំជន ______ រដ្ឋ ______ លេខកូដតំបន់ ______

ឈ្មោះរបស់អ្នកបោះឆ្នោត

ខ្ញុំបាទ/នាងខ្ញុំយល់ព្រមធ្វើជាភ្នាក់ងារក្រោមការចាត់តាំងសម្រាប់អ្នកបោះឆ្នោតដែលមានឈ្មោះខាងលើ។
អ្នកបោះឆ្នោតបានអនុញ្ញាតឱ្យខ្ញុំបាទ/នាងខ្ញុំទៅយក ឬប្រគល់ឯកសារសន្លឹកឆ្នោតអវត្តមាន
ឬសន្លឹកឆ្នោតតាមប្រៃសណីយ៍របស់ពួកគេមកវិញ។ ខ្ញុំបាទ/នាងខ្ញុំសូមបញ្ជាក់ថា ខ្ញុំបាទ/នាងខ្ញុំមិនបានគូសអ្វីចំណាំ
ឬផ្លាស់ប្តូរឯកសារសន្លឹកឆ្នោតអវត្តមាន ឬសន្លឹកឆ្នោតតាមប្រៃសណីយ៍ណាមួយរបស់អ្នកបោះឆ្នោតទេ បើគ្មានការណែនាំ
និងមិនមានការអនុញ្ញាតឱ្យខ្ញុំបាទ/នាងខ្ញុំធ្វើដូច្នេះទេនោះ។ ខ្ញុំបាទ/នាងខ្ញុំយល់ថាការថ្លែងមិនពិតអាចរងការផ្តន្ទាទោសក្រោមច្បាប់ 18 Pa. C.S. § 4904។

**ហត្ថលេខារបស់ភ្នាក់ងារដែលបានចាត់តាំង** ______

កាលបរិច្ឆេទថ្ងៃនេះ ______

បានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ 2024